# លោក យឹម សុវណ្ណ ស្នើឱ្យក្រសួងមហាផ្ទៃនិមន្តព្រះសង្ឃរាជ ទេព វង្ស ទៅបំភ្លឺពីករណីបាត់ខ្លួនព្រះសង្ឃ ទីម សាខន

ដោយ : ជ័យ សច្ចៈ

លោក *យឹម សុវណ្ណ* អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ី មណ្ឌលភ្នំពេញ និងជាប្រធានគណៈកម្មការ មហាផ្ទៃ ការពារជាតិ អង្កេត បោសសំអាត និងមុខងារសាធារណៈ របស់រដ្ឋសភា បានស្នើយ៉ាងម៉ឺងម៉ាត់ឱ្យក្រសួងមហាផ្ទៃ និមន្តព្រះសង្ឃរាជ *ទេព វង្ស* ទៅសាកសួរពីករណីបាត់ខ្លួនព្រះសង្ឃ *ទីម សាខន* ជាបន្ទាន់ផង។ ព្រោះតាំងពីមានការចាប់ព្រះសង្ឃ *ទីម សាខន* ផ្សឹករួចមក ក៏បាត់ដំណឹងលោករហូតមកដល់សព្វថ្ងៃនេះ។

ការស្នើសុំរបស់លោក *យឹម សុវណ្ណ* បែបនេះ ត្រូវបានធ្វើឡើងនៅក្នុងជំនួបពិភាក្សាជាមួយតំណាងក្រសួងមហាផ្ទៃ កាលពីព្រឹកថ្ងៃពុធ ទី០២ ខែសីហា ឆ្នាំ២០០៧នេះ។ ហើយតំណាងក្រសួងមហាផ្ទៃ ដែលបានចូលមកបំភ្លឺតាមការអញ្ជើញរបស់លោក *យឹម សុវណ្ណ* ប្រធានគណៈកម្មការទី៤ នៃរដ្ឋសភា ក្នុងពេលនោះ រួមមាន *ឯម សំអាន* រដ្ឋលេខាធិការក្រសួងមហាផ្ទៃ, *ម៉ៅ ច័ន្ទតារា*, *ផៃ ស៊ីផាន*, *ឥន្ទ សំអឿន* និង *ខួង សុផល* ។

ចំណែក គណៈកម្មការទី៤ នៃរដ្ឋសភាវិញ រួមមានលោក យឹម សុវណ្ណជាប្រធាន,លោក *ប៉ាល់ សំអឿន* . លោក *សោម ចិន*. លោក *ថៃម សាវ៉ៃ* និងលោក *សាយ មង្គល* ។ ក្នុងនោះតំណាង ក្រសួងមហាផ្ទៃបានរាយការណ៍ជូនលោក *យឹម សុវណ្ណ* ពីដំណើរការស៊ើបអង្កេតករណីបាត់ខ្លួន ព្រះសង្ឃ *ទីម សាខន* នេះ ដែលកំពុងស្ថិតនៅក្នុងតំណាក់កាល ស្រាវជ្រាវជាបន្តបន្ទាប់ទៀត នៅឡើយទេ។

បានសេចក្តីថា ករណីបាត់ខ្លួនព្រះសង្ឃ *ទីម សាខន* ក្រោយពេលចាប់ផ្សឹក កាលពីថ្ងៃទី៣០ ខែមិថុនា កន្លងមកនោះ នៅតែពុំទាន់បានទទួលលទ្ធផលអ្វីទាល់តែសោះ។ ហើយបើយោងតាមសម្តីតំណាងក្រសួងមហាផ្ទៃ ក្នុងពេលនោះវិញ គឺគេកំពុងតែព្យាយាម សហការជាមួយអ្នកជាប់ពាក់ព័ន្ធទាំងអស់ ដើម្បីស្រាវជ្រាវរកព្រះសង្ឃ *ទីម សាខន*ជាបន្តទៀត។

ទាក់ទិននឹងការ លើកឡើងរបស់តំណាងក្រសួងមហាផ្ទៃបែបនេះ ត្រូវបានលោក *យឹម សុវណ្ណ* អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ីមណ្ឌលភ្នំពេញ និងជាប្រធានគណៈកម្មការទី៤ នៃរដ្ឋសភា ស្នើយ៉ាងម៉ឺងម៉ាត់ថា *"ខ្ញុំសុំឱ្យខាងក្រសួងមហាផ្ទៃ និមន្តព្រះសង្ឃរាជ ទេព វង្ស ទៅបំភ្លឺចំពោះក្រសួងផង ព្រោះអីករណីចាប់ ព្រះសង្ឃ ទីម សាខន ផ្សឹកដោយ ព្រះសង្ឃរាជ ទេព វង្ស ភ្លាម ក៏បាត់ខ្លួនព្រះសង្ឃ ទីម សាខន ភ្លាមដែរ"*។

លោក *យឹម សុវណ្ណ* បានមានប្រសាសន៍បន្តទៀតថា តាមរបាយការណ៍ ដែលគួរឱ្យយើងជឿជាក់បាននោះ ថាមានអង្គរក្សនាំព្រះតេជគុណ *ទីម សាខន* តាមរថយន្តមួយគ្រឿងចេញទៅ រួចក៏បាត់ខ្លួនព្រះតេជគុណជារៀងរហូតមក ដោយគ្មានដំណឹងអ្វីទាំងអស់។ ហើយនៅក្នុងរបាយការណ៍មួយចំនួន ដែលជាការបំភ្លឺ របស់ព្រះសង្ឃរាជ *ទេព វង្ស* នោះ គឺមានសង្ឃដីកាថា ព្រះសង្ឃ *ទីម សាខន* ផ្សឹកហើយ តែគេសុំទៅស្រុកកំណើតនៅកម្ពុជាក្រោមវិញ។

ចំណុចនេះ ត្រូវបានលោក *យឹម សុវណ្ណ* អត្ថាធិប្បាយថា ខាងវៀតណាមបានបញ្ជាក់ថា គេមិនបានឃើញព្រះសង្ឃ *ទីម សាខន* នេះទៅបំពេញបែបបទចូលប្រទេសវៀតណាមទេ។ ហើយខាងបងប្អូន ព្រះសង្ឃ *ទីម សាខន* នៅឯកម្ពុជាក្រោមវិញ ក៏ដើររកលោកសព្វកន្លែងដែរ តែមិនឃើញដដែល។ បានសេចក្តីថា នៅក្នុងប្រទេសកម្ពុជាក៏មិនឃើញ នៅឯប្រទេសវៀតណាមក៏មិនឃើញ តើព្រះសង្ឃ *ទីម សាខន* ត្រូវអង្គរក្សចាប់ដាក់ឡានយកទៅលាក់ នៅឯណា ? តើលោកនៅរស់ ឬក៏ត្រូវគេសម្លាប់បាត់ទៅហើយ ?

លោក *យឹម សុវណ្ណ* បានបញ្ជាក់ច្បាស់ថា នេះជាសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ ដែលត្រូវតែទទួលខុសត្រូវ នៅចំពោះមុខប្រជាពលរដ្ឋហើយ។ ម្យ៉ាងទៀតករណីដែលពាក់ព័ន្ធនឹងព័ត៌មានតាមវិទ្យុសាយវៀតណាមមួយនិយាយថា ព្រះសង្ឃ *ទីម សាខន* ត្រូវបានតុលាការនៅប្រទេសវៀតណាម កាត់ទោសពីបទធ្វើឱ្យបែកបាក់ ចំណងសាមគ្គីភាព មិត្តភាពកម្ពុជា-វៀតណាមនោះ ត្រូវបានលោក *យឹម សុវណ្ណ* ជម្រុញឱ្យក្រសួងមហាផ្ទៃ ធ្វើការស៊ើបអង្កេតឱ្យបានច្បាស់លាស់ផងដែរ។

ប្រធានគណៈកម្មការទី៤ នៃរដ្ឋសភារូបនេះ បានសង្កត់ធ្ងន់ចំពោះព័ត៌មាន ខាងលើថា *"បើសិនជាករណីព្រះសង្ឃ ទីម សាខន លោកបានប្រព្រឹត្តខុសនឹងវិន័យ ឬក៏ធ្វើអ្វីមួយនាំឱ្យខូចដល់ទំនាក់ទំនង ឬក៏ពាក់ព័ន្ធនឹងបទល្មើស ព្រហ្មទណ្ឌណាមួយនោះ គួរណាស់តែធ្វើឱ្យស្របទៅតាមនីតិវិធីច្បាប់ មិនមែនចាប់បង្ខំ ហើយពង្រត់លោកយកទៅបាត់ដំណឹងបែបនេះទេ"*។

លោក *យឹម សុវណ្ណ* បានមានប្រសាសន៍ថា លោកនឹងបន្តការតាមដាន ដោយយកចិត្តទុកដាក់បំផុត ចំពោះករណីនេះ ព្រោះវាជាការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរណាស់។ ហើយលោកក៏បានសម្តែងនូវការងឿងឆ្ងល់ផងដែរថា ករណីបាត់ខ្លួនព្រះសង្ឃ *ទីម សាខន* គឺជារឿងស្រាលបំផុត ហេតុអ្វីក៏ក្រសួងមហាផ្ទៃធ្វើឱ្យស្មុគស្មាញយ៉ាងដូច្នេះ ? ចំណែករឿងធំៗ ដូចជា ការដាក់គ្រាប់បែកថ្មៃនៅស្តូបមិត្តភាពខ្មែរ-យួន ហេតុអ្វីក៏គេរកមុខ ជនសង្ស័យបានយ៉ាងទាន់ហន់ម្លេះ ?

ជាមួយគ្នានេះដែរ លោក *យឹម សុវណ្ណ* បានលើកឡើងថា មានករណីច្រើនណាស់ដែលក្រសួងមហាផ្ទៃ ធ្វើការងារមានបេសិទភាពគួរឱ្យកត់សមាល់

លោក *យឹម សុវណ្ណ* បានគូសបញ្ជាក់ថា លោកនឹងសិក្សាអំពីផ្លូវច្បាប់ តើអាចនិមន្តព្រះសង្ឃរាជមកបំភ្លឺបាន ឬក៏អត់ ? ព្រោះថា ការនិមន្តព្រះសង្ឃរាជ *ទេព វង្ស* មកបំភ្លឺនោះ គ្រាន់តែចង់បានកិច្ចសហការព័ត៌មានខ្លះៗ ដើម្បីជាការជួយពន្លឿនដល់ដំណើរការស៊ើបអង្កេត របស់ក្រសួងមហាផ្ទៃ និងជួយពន្លឿនដល់កិច្ចខិតខំប្រឹងប្រែង របស់គណៈកម្មការទី៤ របស់រដ្ឋសភាផងដែរ។

គួរបញ្ជាក់ថា ការបាត់ខ្លួនព្រះសង្ឃ *ទីម សាខន* នេះបានធ្វើឱ្យមានប្រតិកម្មយ៉ាងកងរំពងពេញពិភពលោក ហើយក៏មានការគ្រោងធ្វើ មហាបាតុកម្មនៅជុំវិញពិភពលោក ព្រមទាំងដាក់ពាក្យបណ្តឹងទៅតុលាការអន្តរជាតិថែមទៀតផង៕

Yim Sovann summons the Ministry of Interior (MoI) to invite the Supreme Patriarch Tep Vong to appear before Parliament's Committee 4 to testify the missing case of Ven. Tim Sakhorn. Moneaksekar Khmer 08/07/07